# ប្រទេសកម្ពុជា

ព្រឹត្តិបត្រសង្ខេបអំពីតម្លាភាពថវិកា លេខ០៤ | ខែមករា ឆ្នាំ២០១៣

Open Budget Survey 2012
www.openbudgetindex.org

# 15

សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា

— នៃ ១០០ ពិន្ទុ —

| | |
|---|---|
| 81-100 | មានបរិបូណ៌ |
| 61-80 | មានច្រើន |
| 41-60 | មានមួយចំនួន |
| 21-40 | មានតិចតួច |
| **0-20** | **មិនគ្រប់គ្រាន់ឬគ្មាន** |

តើប្រទេសកម្ពុជាមានស្ថានភាពយ៉ាងដូចម្តេចធៀបទៅនឹងប្រទេសជិតខាងរបស់ខ្លួន?




តើពិន្ទុ OBI ប្រទេសកម្ពុជាប្រែប្រួលយ៉ាងណាពីឆ្នាំ២០០៨ ទៅឆ្នាំ២០១២?




## តើអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា ឆ្នាំ២០១២ ជាអ្វី?

**អង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា** (OBS)[១] វាយតម្លៃថាតើរដ្ឋាភិបាលកណ្តាលនៅក្នុងប្រទេសនីមួយៗ ដែលបានធ្វើអង្កេតបានផ្សព្វផ្សាយឯកសារថវិកាសំខាន់ៗចំនួនប្រាំបីជាសាធារណៈឬទេ និងបានផ្សព្វផ្សាយយ៉ាងដូចម្តេច ហើយវាយតម្លៃថាតើទិន្នន័យ ដែលមាននៅក្នុងឯកសារទាំងនោះ មានភាពពេញលេញ ទាន់ពេលវេលា និងមានសារៈប្រយោជន៍ដែរឬយ៉ាងណា។ ធ្វើឡើងរៀងរាល់ពីរឆ្នាំម្តង អង្កេតនេះក៏វាយតម្លៃលើវិសាលភាពនៃ ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាព របស់ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល ព្រមទាំងវាយតម្លៃលើឱកាសសម្រាប់ការចូលរួមរបស់សាធារណជន នៅក្នុងដំណើរការថវិកាជាតិ។

ស្ថាប័នអន្តរជាតិនានា រដ្ឋាភិបាលនៃប្រទេសជាច្រើន និងអ្នកជំនាញឯករាជ្យ សុទ្ធសឹងយល់ស្របថា ដើម្បីធានាឲ្យមានការគ្រប់គ្រងប្រាក់កាសសាធារណៈប្រកបដោយប្រសិទ្ធផល និងស្របតាមតម្រូវការរបស់ប្រទេសមួយ ការទទួលបានព័ត៌មានថវិកាជាសាធារណៈ ការចូលរួមរបស់សាធារណជន និងស្ថាប័នត្រួតពិនិត្យដែលឯករាជ្យ និងរឹងមាំ ពិតជាចាំបាច់ពុំអាចខ្វះបាន។ បើគ្មានយន្តការទាំងនេះទេ នោះស្ថាប័នត្រួតពិនិត្យ អង្គការសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជនទូទៅ មិនអាចចូលរួមប្រកបដោយប្រសិទ្ធភាព នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ហើយអ្នកពាក់ព័ន្ធទាំងនេះ ក៏មិនអាចទាមទារឲ្យស្ថាប័ននីតិប្រតិបត្តិ មានគណនេយ្យភាពចំពោះការប្រើប្រាស់ធនធានសាធារណៈឡើយ។

ដូចអង្កេតមុនៗដែរ (ឆ្នាំ២០០៦ ២០០៨ និង២០១០) **អង្កេត OBS ឆ្នាំ២០១២** ពុំមែនជាការស្ទង់មតិនោះទេ ប៉ុន្តែគឺជា**ការបង្ហាញពីសភាពពិត នៃតម្លាភាព និងគណនេយ្យភាពថវិកា និងការចូលរួមនៅក្នុងដំណើរការថវិកាជាតិ** ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលមានការទទួលស្គាល់ជាអន្តរជាតិ និងប្រើវិធីសាស្ត្រហ្មត់ចត់ និងដែលធ្វើឡើងដោយអ្នកជំនាញឯករាជ្យលើផ្នែកថវិកា។ អង្កេតនេះមានសំណួរចំនួន១២៥ ហើយគ្របដណ្តប់លើប្រទេសចំនួន១០០

## របកគំហើញសំខាន់ៗ

- ពិន្ទុ OBI ឆ្នាំ២០១២ របស់ប្រទេសកម្ពុជាដែលស្មើនឹង ១៥ គឺស្ថិតនៅដដែល ធៀបនឹងពិន្ទុកាលពីឆ្នាំ២០១០ ដែលពិន្ទុនេះ មានកម្រិតទាបជាងច្រើន ធៀបនឹងពិន្ទុមធ្យមជាសាកលដែលស្មើនឹង ៤៣ និងពិន្ទុមធ្យមប្រចាំតំបន់ដែលស្មើនឹង ៣២។
- ពិន្ទុនេះបង្ហាញថា រាជរដ្ឋាភិបាលផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ស្តីពីថវិកា និងសកម្មភាពហិរញ្ញវត្ថុនានា របស់រដ្ឋាភិបាលនៅថ្នាក់ជាតិ ដល់សាធារណជន នៅក្នុងកំឡុងឆ្នាំថវិកា។
- ភាពខ្លាំងរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូលរបស់ប្រទេសកម្ពុជា គឺមានកម្រិតបង្គួរ ខណៈដែលប្រទេសជិតខាង (លើកលែងប្រទេសភូមា) មានស្ថាប័ននីតិប្បញ្ញត្តិ ដែលមានឥទ្ធិពលចាប់ពីបង្គួរទៅខ្លាំង និងស្ថាប័នសវនកម្មកំពូល ដែលមានឥទ្ធិពលខ្លាំង។
- ឱកាសសម្រាប់ការចូលរួមរបស់សាធារណជន ក្នុងដំណើរការថវិកានៅប្រទេសកម្ពុជាមានតិចតួច។

[១] OBS គឺជាសមាសភាពចំបងមួយ នៃ **កម្មវិធីគំនិតផ្តួចផ្តើមនៃការផ្សព្វផ្សាយព័ត៌មានថវិកា** ដែលបានបង្កើតឡើងដោយ **អង្គការភាពជាដៃគូថវិកាអន្តរជាតិ** (IBP) ដើម្បីលើកកម្ពស់ ការទទួលបានព័ត៌មានថវិការបស់សាធារណជន និងជម្រុញឲ្យមានការអនុម័តជាសាកលនូវប្រព័ន្ធថវិកាដែលមានគណនេយ្យភាព និងការចូលរួម។ សម្រាប់ព័ត៌មានបន្ថែមស្តីពីគំនិតផ្តួចផ្តើមនេះ និងអង្កេតនៃការផ្សព្វផ្សាយព័ត៌មានថវិកាទាំងបួនលើកដែលរួមមាន របាយការណ៍ពិស្តារ និងទិន្នន័យដ៏ច្រើន ព្រមទាំងឯកសារថវិកាដែលពាក់ព័ន្ធ សូមចូលទៅកាន់គេហទំព័ររបស់ IBP តាមរយៈ http://internationalbudget.org/

នៅឆ្នាំ២០១២។ ពិន្ទុសម្រាប់សំណួរចំនួន ៩៥ ត្រូវបានប្រើដើម្បីគណនាពិន្ទុមិនលម្អៀងមួយ ដែលឲ្យឈ្មោះថា **សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា** (OBI) សម្រាប់ប្រទេសនីមួយៗដែលត្រូវបានអង្កេត ដោយចាត់ថ្នាក់តម្លាភាពថវិកានៃប្រទេសទាំងនោះ ធៀបនឹងបណ្តាប្រទេសដទៃទៀត។ សំណួរចំនួន ៣០ ទៀត ពាក់ព័ន្ធនឹងការចូលរួមរបស់សាធារណជន និងតួនាទីរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូលនៅក្នុងដំណើរការថវិកា។

## ស្ថានភាពនៃតម្លាភាពថវិកានៅប្រទេសកម្ពុជា

ក្នុងកំឡុងឆ្នាំ២០១០-២០១២ កម្រិតនៃតម្លាភាពថវិកានៅកម្ពុជាមានសភាពនៅទ្រឹង ដូចដែលបានឆ្លុះបញ្ចាំងដោយពិន្ទុ OBI ស្មើនឹង ១៥ នៅឆ្នាំ២០១២។ ពិន្ទុនេះបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាផ្តល់ដល់សាធារណជននូវ ព័ត៌មានមិនគ្រប់គ្រាន់ ស្តីពីថវិកា និងសកម្មភាពហិរញ្ញវត្ថុនានារបស់ខ្លួននៅថ្នាក់ជាតិ ក្នុងកំឡុងឆ្នាំថវិកា។ ប្រការនេះបង្កលក្ខណៈលំបាកដល់ប្រជាពលរដ្ឋ ក្នុងការទាមទារឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រាក់កាសសាធារណៈរបស់ខ្លួន ដែលរួមមាន ការប្រមូលចំណូល និងការប្រើប្រាស់មូលនិធិសាធារណៈនានា ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ក៏ដូចជាក្នុងការធ្វើឲ្យមានឥទ្ធិពលលើគោលនយោបាយទាំងឡាយ ដើម្បីកែលម្អសេវាដែលពួកគេទទួល ដើម្បីលើកកម្ពស់គុណភាពនៃការរស់នៅរបស់ពួកគេ។

## លទ្ធភាពរកបានជាសាធារណៈ នៃឯកសារថវិកាសំខាន់ៗទាំងប្រាំបី

ដូចនៅឆ្នាំ២០១០ដែរ ប្រទេសកម្ពុជាផលិត និងផ្សព្វផ្សាយជាសាធារណៈនូវឯកសារថវិកាចំនួនបួន ក្នុងចំណោមឯកសារថវិកាសំខាន់ៗទាំងប្រាំបី។ ឯកសារទាំងនេះ រួមមាន របាយការណ៍បុរេថវិកា ច្បាប់ថវិកាដែលបានអនុម័ត របាយការណ៍ក្នុងឆ្នាំ និងរបាយការណ៍ដំណាច់ឆ្នាំ ដែលមាននៅក្នុងសៀវភៅរាជកិច្ចរបស់រដ្ឋាភិបាល និងនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (www.mef.gov.kh)។ ឯកសារថវិកាបីផ្សេងទៀត ដែលមិនបានផ្សព្វផ្សាយជាសាធារណៈគឺ សេចក្តីព្រាងច្បាប់ថវិកា របាយការណ៍ពាក់កណ្តាលឆ្នាំ និងរបាយការណ៍សវនកម្ម (ផ្ទៃក្រៅ)។ ប្រទេសកម្ពុជាមិនមានផលិត ឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋឡើយ។

**លទ្ធភាពរកបាន និងភាពគ្រប់គ្រាន់នៃ ឯកសារថវិកាសំខាន់ៗ ចំនួនប្រាំបី ក្នុងឆ្នាំ ២០១២**

| ឯកសារ | ស្ថានភាពផ្សព្វផ្សាយ | កម្រិតពិន្ទុនៃព័ត៌មាន* |
|---|---|---|
| **របាយការណ៍បុរេថវិកា** (សារាចររបស់រាជរដ្ឋាភិបាលស្តីពីគោលការណ៍ណែនាំលើការរៀបចំសេចក្តីព្រាងច្បាប់ថវិកា ឆ្នាំ២០១២) | បានផ្សព្វផ្សាយ | B |
| **សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ** (សេចក្តីព្រាងច្បាប់ថវិកា ឆ្នាំ២០១២) | បានផលិតសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង | E |
| **ថវិកាដែលបានអនុម័ត** (ច្បាប់ថវិកា ឆ្នាំ២០១១) | បានផ្សព្វផ្សាយ | B |
| **ថវិកាសម្រាប់ប្រជាពលរដ្ឋ** | មិនបានផលិត | E |
| **របាយការក្នុងឆ្នាំ** (តារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ឬ TOFE របស់រាជរដ្ឋាភិបាល ឆ្នាំ២០១១) | បានផ្សព្វផ្សាយ | B |
| **របាយការណ៍ពាក់កណ្តាលឆ្នាំ** | បានផលិតសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង | E |
| **របាយការណ៍ដំណាច់ឆ្នាំ** (TOFE ឆ្នាំ ២០១០) | បានផ្សព្វផ្សាយ | D |
| **របាយការណ៍សវនកម្ម** | បានផលិតសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង | E |

* កម្រិតនៃភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាន ដែលបានផ្តល់នៅក្នុងឯកសារនីមួយៗ និងលទ្ធភាពទទួលបានព័ត៌មាននេះ ត្រូវបានគណនាផ្អែកលើមធ្យមភាគពិន្ទុរបស់កម្រងសំណួរ ទាក់ទងនឹងឯកសារនីមួយៗ នៃអង្កេត OBS ឆ្នាំ២០១២។ កម្រិត A តំណាងឲ្យពិន្ទុមធ្យមក្នុងចន្លោះ ៨១-១០០, កម្រិត B៖ ៦១-៨០, កម្រិត C៖ ៤១-៦០, កម្រិត D៖ ២១-៤០, និងកម្រិត E៖ ០-២០។

- **របាយការណ៍បុរេថវិកា** ផ្តល់ព័ត៌មាន (ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឆ្នាំមុន និងឆ្នាំបច្ចុប្បន្ន និងព្យាករណ៍សម្រាប់ឆ្នាំថវិកា ឬឆ្នាំសាររពើពន្ធបន្ទាប់) ដែលផ្សារភ្ជាប់គោលនយោបាយរបស់រដ្ឋាភិបាល ទៅនឹងថវិកា។ របាយការណ៍នេះ គប្បីត្រូវបានផ្សព្វផ្សាយមុន សេចក្តីព្រាងច្បាប់ថវិកា និងជាទូទៅដាក់ចេញនូវប៉ារ៉ាម៉ែត្រទូលំទូលាយ ដែលកំណត់ពីថវិការបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំបន្ទាប់។

ប្រទេសកម្ពុជាផ្សព្វផ្សាយ **សារាចររបស់រាជរដ្ឋាភិបាលស្តីពីគោលការណ៍ណែនាំលើការរៀបចំសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ** នៅក្នុងរាជកិច្ច[២] ចាប់តាំងពីឆ្នាំ២០០៩មក ដែលអាចរកបានជាសាធារណៈដោយបង់ថ្លៃតិចតួច។

- **សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល** ជាឧបករណ៍គោលនយោបាយដ៏សំខាន់បំផុតរបស់រដ្ឋាភិបាល។ ឯកសារនេះ

[២] រាជកិច្ចអាចរកជាវបាននៅ ការិយាល័យនៃអគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ នៃទីស្តីការគណៈរដ្ឋមន្ត្រី។ សារាចរ និងឯកសារថវិកាផ្សេងទៀតដែលប្រើសម្រាប់អង្កេត OBS ឆ្នាំ២០១២ ក៏អាចរកបានផងដែរនៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬគេហទំព័រថវិកាកម្ពុជា www.cambodianbudget.org។

បង្ហាញពីរបៀប ដែលរដ្ឋាភិបាលគ្រោងប្រមូលចំណូលតាមរយៈពន្ធ និងប្រភពផ្សេងទៀត និងចំណាយថវិកាទាំងនេះ សម្រាប់គាំទ្រវិស័យអាទិភាពរបស់ខ្លួន ដើម្បីបម្លែងគោលដៅនៃគោលនយោបាយឲ្យទៅជាសកម្មភាព។

នៅប្រទេសកម្ពុជា សេចក្តីព្រាងច្បាប់ថវិការបស់រដ្ឋាភិបាល ឬ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ** ត្រូវបានផលិតសម្រាប់ប្រើប្រាស់ផ្ទៃក្នុង និងមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយស្ថាប័ននីតិប្រតិបត្តិ ស្របតាមការប្រតិបត្តិល្អជាអន្តរជាតិសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឡើយ។ នៅខែវិច្ឆិកា ឆ្នាំ២០១០ សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១១ ត្រូវបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋសភា ផ្តល់តាមសំណើមកឲ្យ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ ប៉ុន្តែតាំងពីឆ្នាំ២០១១ មក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានបញ្ចេញឯកសារនេះទៀតឡើយ។ ដោយឡែក រដ្ឋសភាជាតិមានសមត្ថកិច្ចពេញលេញ ក្នុងការផ្តល់សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ប៉ុន្តែមិនបានបញ្ចេញឯកសារនេះទេក្នុងឆ្នាំ២០១១ ហើយក្នុងឆ្នាំ២០១២ បញ្ចេញតែសេចក្តីព្រាងច្បាប់ ដោយមិនមានភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធពិស្តារស្តីពីគម្រោងចំណូល និងវិភាជន៍ថវិកា។

◆ **ថវិកាដែលបានអនុម័ត** ក្លាយជាច្បាប់របស់ប្រទេស និងជាឧបករណ៍ស្របច្បាប់មួយដែលផ្តល់សមត្ថកិច្ចដល់ ស្ថាប័ននីតិប្រតិបត្តិក្នុងការប្រមូលចំណូល ធ្វើការចំណាយ និងបង្កើតបំណុលនានា។ ឯកសារនេះ ផ្តល់នូវព័ត៌មានមូលដ្ឋានសម្រាប់ការវិភាគថវិកាទាំងអស់ ដែលធ្វើឡើងក្នុងឆ្នាំថវិកានេះ។ ដូច្នេះ វាគឺជាចំណុចចាប់ផ្តើមនៃកិច្ចប្រឹងប្រែងទាំងឡាយ ដើម្បីតាមដានការអនុវត្តច្បាប់ថវិកា។ ជាទូទៅ ថវិកាដែលបានអនុម័ត គួរផ្តល់ជូនសាធារណជននូវទិន្នន័យចាំបាច់ដែលគេអាចប្រើប្រាស់បាន សម្រាប់វាយតម្លៃអាទិភាពគោលនយោបាយរបស់រដ្ឋាភិបាល និងទាមទារឲ្យរដ្ឋាភិបាលទទួលខុសត្រូវលើការអនុវត្តថវិកា។

ប្រទេសកម្ពុជាផ្សព្វផ្សាយច្បាប់ថវិកា ឬ**ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ** នៅក្នុងសៀវភៅរាជកិច្ច ប៉ុន្តែឯកសារនេះមិនមាន ព័ត៌មានលម្អិតស្តីពីចំណាយនៅកម្រិតថ្នាក់កម្មវិធីទេ។ ការផ្សព្វផ្សាយច្បាប់ថវិកាប្រចាំឆ្នាំទាំងនេះ ក៏ត្រូវបានសង្កេតឃើញថា មានលក្ខណៈរប៉ាត់រប៉ាយ តាមប្រភពសាធារណៈមួយចំនួនផ្សេងគ្នា ដូចជា នៅលើគេហទំព័ររបស់រដ្ឋសភាជាតិ[៣] គេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[៤] និងគេហទំព័ររបស់នាយកដ្ឋានពន្ធដារ[៥] នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

◆ **ថវិកាសម្រាប់ប្រជាពលរដ្ឋ** គឺជាការបង្ហាញដែលមិនមានលក្ខណៈបច្ចេកទេស (ឯកសារសម្រាយមានលក្ខណៈសាមញ្ញ) ស្តីពីថវិការបស់រដ្ឋាភិបាល ដែលមានគោលបំណងជួយឲ្យសាធារណជន (រួមទាំងអ្នកដែលមិនធ្លាប់ដឹងឮអំពីហិរញ្ញវត្ថុសាធារណៈ) អាចយល់ដឹងអំពីផែនការរបស់រដ្ឋាភិបាលក្នុងការប្រមូលចំណូល និងចំណាយមូលនិធិសាធារណៈទាំងនេះ។

ថ្វីបើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្លាប់បានផលិតម្តងនូវ "ថវិកាសង្ខេប" ដែលបង្ហាញពីតួលេខសរុបខ្លះៗស្តីពីចំណូល ចំណាយ និងសូចនាករម៉ាក្រូសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០០៧ក្តី ក៏គេសង្កេតឃើញថាឯកសារនេះមិនត្រូវបានបោះផ្សាយជាបន្តទៀតទេ។ ការបោះផ្សាយឡើងវិញនូវឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋ មានសារៈសំខាន់ណាស់ក្នុងការជួយលើកកម្ពស់ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផែនការរបស់រាជរដ្ឋាភិបាលក្នុងការប្រើប្រាស់ថវិការបស់ពួកគេ និងអាចបញ្ជាក់ពីគណនេយ្យភាពដ៏សមរម្យ ចំពោះប្រជាពលរដ្ឋខ្លួន។ លក្ខណៈនេះ នឹងជួយជម្រុញឲ្យមានតម្រូវការសាធារណៈបន្ថែមទៀតសម្រាប់ព័ត៌មានថវិកា និងការយកចិត្តទុកដាក់បន្ថែមក្នុងការស្វែងយល់ និងតាមដានថវិការបស់ពួកគេ ដែលប្រការនេះជួយឲ្យពួកគេអាចចូលរួមប្រកបដោយប្រសិទ្ធភាព ក្នុងដំណើរការថវិកាជាតិ។

ក្រៅពីអវត្តមាននៃឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋ កង្វះនូវឯកសារណែនាំសម្រាយស្តីពីដំណើរការថវិកាជាតិទាំងមូល រួមមានពាក្យពេចន៍បច្ចេកទេសថវិកា រារាំងកាន់តែខ្លាំងដល់ប្រជាពលរដ្ឋដែលចាប់អារម្មណ៍ និងភាគីពាក់ព័ន្ធនានា ដូចជាសង្គមស៊ីវិល ដែលធ្វើការតាមវិស័យ ក្នុងការស្វែងយល់អំពីលក្ខណៈបច្ចេកទេសនៃថវិកា។ ដូចដែលបានសង្កេតកន្លងមក មិនមានសទ្ទានុក្រម ឬវចនានុក្រម (ខ្មែរ) ស្តីពីពាក្យពេចន៍បច្ចេកទេសថវិកា ត្រូវបានផលិតឡើងសម្រាប់ផ្សព្វផ្សាយជាសាធារណៈ ឬជួយជម្រុញឲ្យមានការចូលរួមជាសាធារណៈនោះទេ លើកលែងតែពាក្យពេចន៍គន្លឹះ និងពាក្យពេចន៍ថវិកាមួយចំនួនតូច ដែលត្រូវបានពន្យល់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងប្រកាសលេខ១៤៤៨ សហវ.ប្រ.ក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ។ ផ្អែកលើការយល់ដឹងរបស់យើងខ្ញុំកន្លងមក ឯកសារទាំងពីរនេះជាសទ្ទានុក្រម និងឯកសារណែនាំតែពីរគត់ ដែលអាចរកបានជាសាធា-

[៣] ប៉ុន្តែមានតែច្បាប់ដែលបានអនុម័តក្នុងអាណត្តិទីមួយ ទីពីរ និងទីបីប៉ុណ្ណោះ ដែលអាចទាញយកបានពីគេហទំព័ររបស់រដ្ឋសភា(www.natonal-assembly.org.kh)។ គេសង្ឃឹមថា ច្បាប់ដែលបានអនុម័តក្នុងអាណត្តិទីបួន(ឆ្នាំ២០០៨-បច្ចុប្បន្ន) នឹងអាចទាញយកបាននាពេលដ៏ខ្លីខាងមុខ។

[៤] ច្បាប់ថវិកាឆ្នាំ២០១៣ (www.mef.gov.kh/budget.html)។

[៥] ច្បាប់ថវិកា ចាប់ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១០ ដោយមានបាត់ឆ្នាំខ្លះ (http://www.tax.gov.kh/taxtypes.php)។

រណៈ សម្រាប់អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ប្រើប្រាស់ក្នុងការដោះស្រាយបញ្ហាប្រឈមផ្នែកបច្ចេកទេស នៅក្នុងការងារតាមដានថវិការបស់ពួកគេ។

ផ្អែកលើរបាយការណ៍ប្រចាំត្រីមាសទីមួយ ឆ្នាំ២០១២ ស្តីពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គេបានដឹងថា ការរៀបចំចងក្រងសន្ទានុក្រម[៦] និងឯកសារគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងដំណើរការ។ វាមានសារៈសំខាន់ណាស់ ប្រសិនបើឯកសារណែនាំទាំងនេះនឹងត្រូវបានផ្សព្វផ្សាយផងដែរដល់សាធារណជនទូទៅ ដើម្បីជម្រុញឲ្យមានការចូលរួមយ៉ាងពេញលេញ នៅក្នុងដំណើរការថវិកា បន្ថែមពីលើការជួយពង្រឹងសមត្ថភាពរបស់ក្រសួងសាមី ក្នុងការពន្លឿនកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

◆ **របាយការណ៍ក្នុងឆ្នាំ** ផ្តល់នូវរបាយការណ៍សង្ខេបមួយអំពីប្រសិទ្ធភាពនៃការអនុវត្តថវិកានៅក្នុងឆ្នាំថវិកា។ គោលបំណងចម្បងនៃការផ្សព្វផ្សាយរបាយការណ៍នេះ គឺដើម្បីផ្តល់ការវាស់វែងជាទៀងទាត់មួយលើនិន្នាការនៃការប្រមូលចំណូល និងចំណាយជាក់ស្តែង ដែលអនុញ្ញាតឲ្យមានការប្រៀបធៀបជាមួយ តួលេខនៅក្នុងច្បាប់ថវិកា និងការកែតម្រូវថវិកា។

របាយការណ៍ក្នុងឆ្នាំរបស់កម្ពុជា ឬតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ (TOFE) ផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយខ្លះៗ ប៉ុន្តែតារាងនេះខ្វះសេចក្តីលម្អិតសំខាន់ៗមួយចំនួនដូចជា បំណែងចែកចំណាយតាមក្រសួងសាមី ការពន្យល់លម្អិតអំពីភាពខុសគ្នារវាងចំណូល និងចំណាយជាក់ស្តែង និងក្នុងផែនការ ព្រមទាំងការធ្វើបច្ចុប្បន្នកម្ម ឬការចេញផ្សាយឲ្យបានទៀងទាត់លើគេហទំព័ររបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ ប្រភពសាធារណៈឯទៀត។ ពេលវេលានៃការចេញផ្សាយ TOFE ប្រចាំខែនីមួយៗ មិនមានភាពទៀងទាត់ទេ ហើយជួនកាលឯកសារនេះត្រូវបានចេញផ្សាយលើសពីពីរខែ ក្រោយខែដែលត្រូវបានរាយការណ៍។ ការចេញផ្សាយយឺតនេះ អាចបណ្តាលជាចម្បងមកពីតម្រូវការពេលវេលាសម្រាប់ការសម្របសម្រួល និងការបញ្ជាក់តួលេខតាមនាយកដ្ឋាននានារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាសម្រាប់ការអនុម័តរបស់គណៈគ្រប់គ្រង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅលើ TOFE ប្រចាំខែ មុននឹងចេញផ្សាយនៅលើគេហទំព័រសម្រាប់ការប្រើប្រាស់ជាផ្លូវការ[៧]។ ទោះជាយ៉ាងនេះក្តី យើងសង្ឃឹមយ៉ាងមុតមាំថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងប្រឹងប្រែងបន្ថែមទៀត ដើម្បីចេញផ្សាយតារាង TOFE ឲ្យបានកាន់តែទាន់ពេលវេលា និងទៀងទាត់នៅក្នុងពេលអនាគត។

◆ **របាយការណ៍ពាក់កណ្តាលឆ្នាំ** ផ្តល់នូវទិដ្ឋភាពរួមមួយអំពីប្រសិទ្ធភាពនៃ ការអនុវត្តថវិកានៅពាក់កណ្តាលឆ្នាំថវិកា។ ព័ត៌មាននៅក្នុងរបាយការណ៍នេះ អនុញ្ញាតឲ្យគេវាយតម្លៃស្ថានភាពសារពើពន្ធរបស់រដ្ឋាភិបាល ដោយប្រៀបធៀបនឹងផែនការដែលបានដាក់ចេញនៅក្នុងច្បាប់ថវិកាដើម។ វាអនុញ្ញាតឲ្យរដ្ឋាភិបាល ស្ថាប័ននីតិប្បញ្ញត្តិ និងសាធារណជន អាចកំណត់បានថាតើគួរមានការកែតម្រូវឬយ៉ាងណាទាក់ទិននឹងចំណូល ចំណាយ ឬកម្ចីនៅក្នុងរយៈពេលប្រាំមួយខែចុងក្រោយនៃឆ្នាំថវិកា។

នៅប្រទេសកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបោះផ្សាយម្តងនូវរបាយការណ៍ពាក់កណ្តាលឆ្នាំ នៃការអនុវត្តច្បាប់ថវិកាឆ្នាំ២០១០ ព្រមជាមួយនឹងឯកសារស្តីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០០០-២០១១ នៅលើគេហទំព័ររបស់ខ្លួន។ នេះគឺស្តែងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឲ្យប្រសើរឡើងនូវតម្លាភាពថវិកា បើទោះបីជាមាត្រា៣៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ តម្រូវត្រឹមតែឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្តល់នូវរបាយការណ៍នេះ និងរបាយការណ៍ដំណាច់ឆ្នាំដល់រដ្ឋសភា និងព្រឹទ្ធសភានៅពាក់កណ្តាលឆ្នាំ និងនៅពេលពិភាក្សាអនុម័តសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំបន្ទាប់ក្តី[៨]។ យ៉ាងណាមិញ ចាប់តាំងពីឆ្នាំ២០១១ មក របាយការណ៍ពាក់កណ្តាលឆ្នាំ មិនត្រូវបានផ្សព្វផ្សាយទៀតឡើយ។ ការផ្សព្វផ្សាយឯកសារនេះ មានសារៈសំខាន់ណាស់ ដោយវានឹងបង្ហាញនូវជំហានវិជ្ជមានមួយ របស់រាជរដ្ឋាភិបាលក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីរួមបញ្ចូលសាធារណជនទៅក្នុងដំណើរការថវិកា ទោះបីជាមានឬមិនមានតម្រូវការពីសាធារណជនក្តី ដែលតម្រូវការនេះអាចនៅមានកម្រិតទាបនាពេលបច្ចុប្បន្ន តែកំពុងនឹងកើនឡើងជាលំដាប់។ ការផ្សព្វផ្សាយឯកសារនេះ ក៏បញ្ជាក់ផងដែរពីការបំពេញកាតព្វកិច្ចផ្លូវច្បាប់របស់រាជរដ្ឋាភិបាល ដូចដែលមានចែងនៅក្នុងមាត្រា៨៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលតម្រូវឲ្យមានការផ្សព្វផ្សាយជាសាធារណៈ នូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍គណនេយ្យទាំងអស់។ ជាងនេះទៅទៀត ការផ្សព្វផ្សាយនូវរបាយការណ៍ពាក់កណ្តាលឆ្នាំនេះ ក៏ដូចជាឯកសារថវិកាដទៃទៀត ត្រូវការចំណាយធនធានហិរញ្ញវត្ថុយ៉ាងតិចតួច ឬមិនមានចំណាយអ្វីសោះ។ ប្រសិនបើគំនិតផ្តួចផ្តើមក្នុងការផ្សព្វផ្សាយរបាយ

[៦] របាយការណ៍នេះ ត្រូវបានទាញយកពីគេហទំព័រ www.pfm.gov.kh កាលពីថ្ងៃ ទី១៩ ខែមិថុនា ឆ្នាំ២០១២។

[៧] ព័ត៌មានទទួលបានពីកិច្ចប្រជុំរវាងក្រុមការងាររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

[៨] របាយការណ៍ដំណាច់ឆ្នាំ ដែលមានតួលេខបំណែងចែកតាមក្រសួងសាមី និងផលិតសម្រាប់ពេលអនុម័តលើថវិកាឆ្នាំសារពើពន្ធបន្ទាប់ ដែលមិនមានចេញផ្សាយជាសាធារណៈ ផ្តល់ជាតួលេខប៉ាន់ស្មាន។ ចំណែកឯរបាយការណ៍ ដែលពេញលេញ និងកាន់តែមានភាពសុក្រិត្យ ត្រូវបានផលិតក្នុងទម្រង់តួលេខសរុប ក្នុងរយៈពេលបី ទៅបួនខែប៉ុណ្ណោះបន្ទាប់ពីឆ្នាំសារពើពន្ធ ពោលគឺក្នុងខែឧសភា/ខែមិថុនា។

ការណ៍នេះ បន្តមានក្នុងលក្ខណៈជាប្រព័ន្ធ ប្រទេសកម្ពុជាទំនងជាអាចធ្វើឲ្យប្រសើរឡើងនូវ លទ្ធផលជារួមរបស់ខ្លួននៅក្នុងអង្កេត OBS លើកក្រោយទៀត។

◆ **របាយការណ៍ដំណាច់ឆ្នាំ** មានព័ត៌មានដែលប្រៀបធៀបការអនុវត្តថវិកាជាក់ស្តែង ទៅនឹងច្បាប់ថវិកាដែលបានអនុម័ត។ របាយការណ៍នេះ អាចផ្តល់ព័ត៌មានដល់សាធារណជន និងអ្នកធ្វើគោលនយោបាយអំពីគោលនយោបាយពន្ធ និងកាតព្វកិច្ចបំណុល ក៏ដូចជាអាទិភាពចំណាយចម្បងៗសម្រាប់ឆ្នាំថវិកាខាងមុខ។ ម្យ៉ាងទៀត ព័ត៌មានដែលមាននៅក្នុងរបាយការណ៍នេះ អាចជួយដល់ក្រសួងនីមួយៗ និងសាធារណជន ក្នុងការកំណត់ចន្លោះប្រហោងនានានៅក្នុងគោលនយោបាយ និងកម្មវិធីដែលមានស្រាប់ ហើយអាចប្រើបានក្នុងការធ្វើឲ្យមានឥទ្ធិពលលើទិសដៅអនាគត។

នៅប្រទេសកម្ពុជា របាយការណ៍ដំណាច់ឆ្នាំ (ដែលមិនបានឆ្លងកាត់ការធ្វើសវនកម្ម) ឬ TOFE ត្រូវបានគេសម្គាល់ថា បានចេញផ្សាយ ប្រមាណក្នុងកំឡុងឆមាសទីពីរ នៃឆ្នាំសារពើពន្ធបន្ទាប់ នៅលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការចេញផ្សាយរបាយការណ៍នេះឲ្យបានទាន់ពេលវេលា និងទៀងទាត់ មានអត្ថប្រយោជន៍ដល់ការតាមដានថវិកា ព្រមទាំងជួយពង្រឹងតម្លាភាពគណនេយ្យភាព និងការចូលរួមជាសាធារណៈ។ ទម្រង់នៃមាតិកាថវិកាដែលប្រើក្នុងឯកសារនេះ (ក៏ដូចជាក្នុងរបាយការណ៍ក្នុងឆ្នាំ) និងទម្រង់ដែលប្រើប្រាស់ក្នុងច្បាប់ថវិកា រួមទាំងច្បាប់ទូទាត់ថវិកា[៩] ផងមិនមានសង្គតិភាពនឹងគ្នាទេ ។ ប្រការនេះធ្វើឲ្យមានការលំបាកដល់សាធារណជន និងអង្គការសង្គមស៊ីវិល ក្នុងការត្រួតពិនិត្យការអនុវត្តថវិកា ដើម្បីទាមទារឲ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះការអនុវត្តថវិកា។

ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ ដែលមានភាពស្រដៀងគ្នាទៅនឹង TOFE មានបំណែងចែកសរុប នៃតួលេខអនុវត្តថវិកាតាមក្រសួងសាមីព្រមទាំងTOFE ដែលបានធ្វើបច្ចុប្បន្នកម្មចុងក្រោយបំផុត។ ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ អាចរកជាវបាននៅ នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ[១០] នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ យ៉ាងនេះក្តី ដោយសារតែតួលេខទាំងនេះជាតួលេខបណ្តោះអាសន្នដែលភាគច្រើនប្រមូលមកពីអគ្គនាយកដ្ឋានរតនាគារជាតិ គេឃើញមានបញ្ហាកំហុសតួលេខ ជាពិសេសនៅលើបំណែងចែកសរុបនៃតួលេខអនុវត្តថវិកាតាមក្រសួងសាមី ដែលរាយការណ៍នៅក្នុងព្រឹត្តិប័ត្រស្ថិតិក្នុងឆ្នាំ២០១០ ដោយប្រៀបធៀបទៅនឹងតួលេខ ដែលបានរាយការណ៍នៅក្នុងឯកសារស្តីពីការគ្រប់គ្រងថវិកាភាគ១ (ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង៖ ច្បាប់ និងបទប្បញ្ញត្តិ) ឆ្នាំ២០១១ និងឆ្នាំ២០១២។

◆ **របាយការណ៍សវនកម្ម** គឺជាការវាយតម្លៃឯករាជ្យមួយលើគណនីនានារបស់រដ្ឋាភិបាល (ការប្រមូលចំណូល និងចំណាយ) ដោយស្ថាប័នសវនកម្មកំពូលរបស់ប្រទេស។ ឯកសារនេះរាយការណ៍ថាតើរដ្ឋាភិបាលបានប្រមូលចំណូល និងចំណាយថវិកា ស្របតាមថវិកាដែលបានអនុម័តឬទេ និងថាតើគណនីរបស់រដ្ឋាភិបាលគឺត្រឹមត្រូវ និងអាចពឹងផ្អែកបាន ក្នុងការផ្តល់នូវរូបភាពមួយដែលអាចទុកចិត្តបានអំពីស្ថានភាពសារពើពន្ធឬទេ។ របាយការណ៍សវនកម្ម ក៏ផ្តល់ព័ត៌មានផងដែរអំពីបញ្ហាទាំងឡាយណា ដែលត្រូវបានរកឃើញដោយសវនករនៅក្នុងការគ្រប់គ្រងមូលនិធិសាធារណៈនៅក្នុងឆ្នាំថវិកា។

នៅប្រទេសកម្ពុជា របាយការណ៍សវនកម្មលើការអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល តម្រូវឲ្យដាក់ជូនទៅអង្គនីតិប្បញ្ញត្តិនៅមុនពេលអនុម័តច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ។ ទោះបីជារបាយការណ៍នេះត្រូវបានចាត់ទុកថាជាឯកសារសាធារណៈ ដោយមាត្រា២៩ នៃច្បាប់ស្តីពីសវនកម្ម ក៏របាយការណ៍នេះអាចមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ ឬផ្សព្វផ្សាយដោយលុបចោល នូវព័ត៌មានពិស្តារ ប្រសិនបើឯកសារនេះមានព័ត៌មាន ដែលអាចចាត់ទុកថាប៉ះពាល់ដល់ ផលប្រយោជន៍ជាតិ ឬផលប្រយោជន៍ពាណិជ្ជកម្មរបស់អង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល ដូចដែលបានចែងក្នុងមាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់នេះ។

ជាលើកទីមួយ ចាប់តាំងពីពេលបង្កើតឡើងក្នុងឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិ បានផ្សព្វផ្សាយរបាយការណ៍សវនកម្មស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ការអនុវត្តថវិកា) ឆ្នាំ២០០៦ នៅក្នុងខែកញ្ញា ឆ្នាំ២០០៩ (ស្ទើរតែ ៣ឆ្នាំ បន្ទាប់ពីឆ្នាំសារពើពន្ធ) និងរបាយ-ការណ៍សវនកម្មស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៧ ក្នុងខែតុលា ឆ្នាំ២០១១ (ស្ទើរតែ ៤ឆ្នាំ បន្ទាប់ពីឆ្នាំសារពើពន្ធ)។ ដោយសាររបាយការណ៍ទាំងនេះត្រូវបានផ្សព្វផ្សាយ ឬផ្តល់ជូនសាធារណជនតាមសំណើ ក្នុងរយៈពេលយឺតជាងពីរឆ្នាំ ក្រោយពេលបញ្ចប់ឆ្នាំសារពើពន្ធនោះ ការផ្សព្វផ្សាយនេះមិនបានបំពេញតាមស្តង់ដារអប្បបរិមានៃការប្រតិបត្តិល្អ ជាអន្តរជាតិនោះទេ ហើយយោងតាមវិធីសាស្ត្រនៃអង្កេត OBS របាយការណ៍ទាំងនេះត្រូវបានចាត់ទុកថា **បានផលិត ប៉ុន្តែមិនបានផ្សព្វផ្សាយជាសាធារណៈ**។ ការផ្សព្វផ្សាយរបាយការណ៍សវនកម្មឲ្យបានទាន់ពេលវេលា នឹងរឹតតែធ្វើឲ្យប្រសើរឡើងនូវតម្លាភាពថវិកាជាទូទៅរបស់កម្ពុជា ធានានូវឯករាជ្យភាពរបស់អាជ្ញាធរសវនកម្មជាតិ និងបង្កើនពិន្ទុ OBI របស់ប្រទេសកម្ពុជានៅពេលអនាគត។

[៩] ច្បាប់ទាំងពីរនេះ មានទម្រង់ និងទំហំព័ត៌មានដូចគ្នា។

[១០] មានតម្លៃ ២០.០០០រៀល ឬ ៥ ដុល្លារ ក្នុងមួយច្បាប់។

## តើប្រទេសកម្ពុជាមានស្ថានភាពយ៉ាងដូចម្ដេច ធៀបនៅនឹងប្រទេសដទៃទៀត និងប្រទេសជិតខាងរបស់ខ្លួនក្នុងតំបន់អាស៊ីអគ្នេយ៍?

នៅលើឆាកអន្តរជាតិ ប្រទេសកម្ពុជាទទួលបានពិន្ទុទាបជាងច្រើនពីពិន្ទុមធ្យមជាសកល ៤៣ ហើយត្រូវបានចាត់ថ្នាក់ក្នុងចំណោមក្រុមប្រទេសចំនួន ២៦ ដែលផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ជូនដល់សាធារណជនសម្រាប់ឆ្នាំ២០១២។ ក្នុងចំណោមប្រទេសចំនួន ២៣ ដែលបានចាត់ថ្នាក់ក្នុងក្រុមនេះនៅឆ្នាំ២០១០ ប្រទេសចំនួន១៤ បានធ្វើឲ្យកើនឡើងនូវពិន្ទុ OBI របស់ខ្លួនសម្រាប់ឆ្នាំ២០១២ រាប់ទាំងប្រទេសវៀតណាម ដែលបានបង្កើនពិន្ទុរបស់ខ្លួនពី ១៤ សម្រាប់ឆ្នាំ២០១០ ទៅដល់ ១៩ សម្រាប់ឆ្នាំ២០១២។

បើប្រៀបធៀបជាមួយប្រទេសជិតខាងរបស់ខ្លួន និងជាមួយបណ្តាប្រទេសដទៃទៀតនៅអាស៊ីអគ្នេយ៍ ពិន្ទុរបស់ប្រទេសកម្ពុជាស្មើនឹងពាក់កណ្តាលពិន្ទុមធ្យមប្រចាំតំបន់ ៣២ ដែលពិន្ទុនេះ (លើកលែងតែប្រៀបធៀបជាមួយនឹងប្រទេសភូមា[១១] ដែលបានទទួលពិន្ទុ 0) គឺជាពិន្ទុទាបជាងគេនៅក្នុងតំបន់។ ពិន្ទុទាបនេះបង្ហាញថា ប្រជាពលរដ្ឋកម្ពុជា សឹងតែមិនអាចស្វែងរកគណនេយ្យភាពពីរាជរដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងលើប្រាក់កាសសាធារណៈ។

**ការផ្សព្វផ្សាយឯកសារថវិកាតាមប្រទេសនៅអាស៊ីអគ្នេយ៍ ឆ្នាំ២០១២**

| ឯកសារថវិកា | កម្ពុជា | ឥណ្ឌូនេស៊ី | ម៉ាឡេស៊ី | ភូមា | ហ្វីលីពីន | ថៃឡង់ដ៍ | ទីម័រខាងកើត | វៀតណាម |
|---|---|---|---|---|---|---|---|---|
| របាយការណ៍បុរេថវិកា | ✓ | ✓ | NP | NP | IU | NP | NP | ✓ |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល | IU | ✓ | ✓ | IU | ✓ | ✓ | ✓ | IU |
| ថវិកាដែលបានអនុម័ត | ✓ | ✓ | ✓ | IU | ✓ | ✓ | ✓ | ✓ |
| ថវិកាសម្រាប់ប្រជាពលរដ្ឋ | NP | ✓ | NP | NP | NP | ✓ | NP | NP |
| របាយការណ៍ក្នុងឆ្នាំ | ✓ | IU | ✓ | IU | ✓ | ✓ | ✓ | ✓ |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | IU | ✓ | NP | IU | NP | NP | NP | NP |
| របាយការណ៍ដំណាច់ឆ្នាំ | ✓ | ✓ | ✓ | IU | NP | NP | NP | ✓ |
| របាយការណ៍សវនកម្ម | IU | ✓ | ✓ | IU | ✓ | NP | NP | ✓ |

**កំណត់សម្គាល់៖ IU៖** ឯកសារដែលបានរៀបចំសម្រាប់ប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ
**NP៖** ឯកសារមិនបានរៀបចំ និង ✓៖ ឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈ

ប្រទេសកម្ពុជាបានផ្សព្វផ្សាយជាសាធារណៈនូវឯកសារថវិកាចំនួន ៤ ដែលជាចំនួនមួយតិចជាងច្រើន ធៀបនឹងប្រទេសឥណ្ឌូនេស៊ី ដែលបានផលិត និងផ្សព្វផ្សាយឯកសារថវិកាចំនួន ៧ និងប្រទេសម៉ាឡេស៊ី និងវៀតណាម ដែលបានបោះផ្សាយឯកសារថវិកាចំនួន៥។ ប្រទេសហ្វីលីពីន និងប្រទេសថៃ ម្នាក់ៗសុទ្ធតែផ្សព្វផ្សាយឯកសារថវិកាដែលមានចំនួនស្មើគ្នានឹងប្រទេសកម្ពុជា រីឯប្រទេសទីម័រខាងកើតបានផ្សព្វផ្សាយឯកសារថវិកាត្រឹមតែ ៣ ប៉ុណ្ណោះ សម្រាប់ជូនសាធារណជន។ ទោះជាយ៉ាងនេះក្តី ប្រទេសទាំងនេះទទួលបានពិន្ទុខ្ពស់ជាងកម្ពុជាយ៉ាងច្រើន ដោយមូលហេតុចម្បងថា ប្រទេសទាំងនេះបានផលិត និងផ្សព្វផ្សាយជាសាធារណៈ នូវសេចក្តីព្រាងច្បាប់ថវិការបស់រដ្ឋាភិបាល ដែលឯកសារនេះពាក់ព័ន្ធនឹងសំណួរ ៥៨ ក្នុងចំណោមសំណួរចំនួន ៩៥ ដែលគេប្រើក្នុងការគណនាពិន្ទុ OBI ដោយយោងទៅលើសារៈសំខាន់របស់ សេចក្តីព្រាងច្បាប់ថវិកា ក្នុងការជូនដំណឹងដល់សាធារណជនអំពីគម្រោងប្រមូលចំណូល និងចំណាយរបស់រដ្ឋាភិបាល។

សារៈសំខាន់នៃឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋ បានទទួលកម្លាំងគាំទ្រកាន់តែខ្លាំងនៅអាស៊ីអគ្នេយ៍ ដោយប្រទេសឥណ្ឌូនេស៊ី និងប្រទេសថៃ បានចាប់ផ្តើមផលិតឯកសារនេះក្រោយឆ្នាំ២០១០។ ទោះជាយ៉ាងណាក្តី ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេស ៥ ដទៃទៀតនៅក្នុងតំបន់ ដែលមិនផលិតថវិកាសម្រាប់ប្រជាពលរដ្ឋ។

អាស្រ័យហេតុនេះ ប្រទេសកម្ពុជាអាចធ្វើឲ្យចំណាត់ថ្នាក់តម្លាភាពថវិការបស់ខ្លួនកាន់តែប្រសើរឡើង តាមរយៈការបោះផ្សាយ (ឲ្យបានទាន់ពេលវេលា និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ) នូវសេចក្តីព្រាងច្បាប់ថវិកា និងឯកសារថវិកាដទៃទៀត។

## ភាពខ្លាំងរបស់ស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល

បន្ថែមលើការលើកកម្ពស់ការផ្សព្វផ្សាយ និងភាពគ្រប់ជ្រុងជ្រោយនៃឯកសារថវិកាទាំង ៨ គេអាចធ្វើឲ្យដំណើរការថវិការបស់ប្រទេសកម្ពុជាកាន់តែមានលក្ខណៈបើកចំហបន្ថែមទៀត តាមរយៈការអភិវឌ្ឍស្ថាប័ននីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូលឲ្យមានភាពរឹងមាំ ដើម្បីធ្វើការត្រួតពិនិត្យថវិកាប្រកបដោយប្រសិទ្ធិភាព។

នៅប្រទេសកម្ពុជា ភាពខ្លាំងរបស់ស្ថាប័ននីតិប្បញ្ញត្តិគឺបង្គួរ ខណៈដែលនៅក្នុងប្រទេសជិតខាងរបស់ខ្លួន ភាពខ្លាំងនៃស្ថាប័ននេះត្រូវបានចាត់ថ្នាក់ថាបង្គួររហូតដល់ រឹងមាំ លើកលែងតែប្រទេសភូមា។ ការវាយតម្លៃនេះផ្អែកលើសូចនាករចំនួន ១១ រួមមាន៖ ការពិគ្រោះយោបល់ជាមួយស្ថាប័ននីតិប្រតិបត្តិ មុនពេលបញ្ជូនសេចក្តីព្រាងច្បាប់ថវិកាទៅកាន់ស្ថាប័ននីតិប្បញ្ញត្តិ សមត្ថភាពស្រាវជ្រាវ ការជជែក

[១១] ប្រទេសភូមា ជាប្រទេសទើបចូលថ្មីនៅក្នុងអង្កេត OBS។

ដេញដោលជាផ្លូវការអំពីគោលនយោបាយថវិកាទូទៅ ពេលវេលាសម្រាប់ការពិភាក្សា និងអនុម័តថវិកា សមត្ថកិច្ចផ្លូវច្បាប់ក្នុងការកែសម្រួលសំណើថវិកា ការអនុម័តលើការផ្លាស់ប្តូរថវិកាចំណាយ និងចំណូលដែលបានប្រមូលលើស អំណាចលើការប្រើប្រាស់ថវិកាបន្ថែម សមត្ថកិច្ចអនុម័តការប្រើប្រាស់ថវិកាបំរុង និងការត្រួតពិនិត្យរបាយការណ៍សវនកម្ម។

**ប្រទេសកម្ពុជា មិនស្ថិតក្នុងចំណោមប្រទេសអាស៊ីអគ្នេយ៍ ដែលឈានមុខលើការត្រួតពិនិត្យថវិកា និងការចូលរួមរបស់សាធារណជនទេ**

| ប្រទេស | ភាពខ្លាំងនៃស្ថាប័ននីតិប្បញ្ញត្តិ | ភាពខ្លាំងនៃស្ថាប័នសវនកម្មកំពូល | ការចូលរួមរបស់សាធារណជន |
|---|---|---|---|
| កម្ពុជា | បង្គួរ | បង្គួរ | ខ្សោយ |
| ទីម័រខាងកើត | បង្គួរ | រឹងមាំ | ខ្សោយ |
| ឥណ្ឌូនេស៊ី | រឹងមាំ | រឹងមាំ | ខ្សោយ |
| ម៉ាឡេស៊ី | បង្គួរ | រឹងមាំ | ខ្សោយ |
| ភូមា | ខ្សោយ | ខ្សោយ | ខ្សោយ |
| ហ្វីលីពីន | បង្គួរ | រឹងមាំ | បង្គួរ |
| ថៃឡង់ដ៍ | រឹងមាំ | រឹងមាំ | ខ្សោយ |
| វៀតណាម | រឹងមាំ | រឹងមាំ | ខ្សោយ |

**កំណត់សម្គាល់៖** ពិន្ទុជាមធ្យមសម្រាប់ **រឹងមាំ៖** ៦៧-១០០ **បង្គួរ៖** ៣៤-៦៦ និង **ខ្សោយ៖** ០-៣៣។

ក្នុងការអនុវត្តជាក់ស្តែង ស្ថាប័ននីតិប្បញ្ញត្តិកម្ពុជា ទំនងជាជួបការលំបាក ដោយកង្វះព័ត៌មានថវិកាគ្រប់គ្រាន់ សម្រាប់ធ្វើការពិភាក្សាបែបរិភាគ ឬការជជែកដេញដោលពីការគ្រប់គ្រងមូលនិធិសាធារណៈ ក្នុងអំឡុងពេលអនុម័តច្បាប់ថវិកា។ ដូចដែលបានសង្កេតកន្លងមក ព័ត៌មានថវិកាដែលបានបញ្ជូនទៅរដ្ឋសភាជាតិ ត្រូវបានកាត់បន្ថយច្រើន។ ចាប់តាំងពី ឆ្នាំ២០១០មក តួលេខប៉ាន់ស្មានការអនុវត្តថវិកាសម្រាប់ឆ្នាំសារពើពន្ធមុន ត្រូវបានដកចេញពីសេចក្តីព្រាងច្បាប់ថវិកា ដោយទុកតែតួលេខវិភាជន៍តែប៉ុណ្ណោះ សម្រាប់ឲ្យរដ្ឋសភាជាតិអនុម័ត។ តារាងសង្ខេបស្តីពីការអនុវត្តថវិកាសម្រាប់ឆ្នាំមុនៗដែលរៀបតាមទម្រង់ចំណាត់ថ្នាក់ថវិកាផ្សេងៗ និងព័ត៌មានស្តីពីបុគ្គលិកហាក់ដូចជាត្រូវបានដកចេញពី សេចក្តីថ្លែងហេតុដែលអមសេចក្តីព្រាងច្បាប់ថវិកា។ បន្ថែមលើនេះ របាយការណ៍ពាក់កណ្តាលឆ្នាំ នៃការអនុវត្តច្បាប់ថវិកា២០១០ ដែលបានដាក់ជូនទៅរដ្ឋសភាជាតិ និងដែលត្រូវបានផ្សព្វផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅលើគេហទំព័ររបស់ក្រសួង ក៏ផ្តល់ត្រឹមតែព័ត៌មានថវិកាសរុប ដោយគ្មានភ្ជាប់តួលេខស្តីពីការអនុវត្តថវិកាលម្អិត សម្រាប់ឲ្យសមាជិក-សមាជិកានៃរដ្ឋសភាជាតិ ពិនិត្យឲ្យបានហ្មត់ចត់ឡើយ។ ឧបសគ្គទាំងនេះអាចរឹតត្បិតសមត្ថភាពរបស់សមាជិក-សមាជិកា នៃរដ្ឋសភាជាតិ ក្នុងការយល់អំពីស្ថានភាព និងបញ្ហាថវិកា ហើយអាចមិនជម្រុញឲ្យមានការជជែកដេញដោលច្រើន លើសេចក្តីព្រាងច្បាប់ថវិកា ពីសំណាក់សមាជិក-សមាជិកានៃរដ្ឋសភាជាតិ ក៏ដូចជាការតាមដាន និងត្រួតពិនិត្យថវិកាឲ្យមានប្រសិទ្ធភាពបានឡើយ។

ដូចករណីស្ថាប័ននីតិប្បញ្ញត្តិដែរ ភាពខ្លាំងរបស់ស្ថាប័នសវនកម្មកំពូលកម្ពុជា ឬអាជ្ញាធរសវនកម្មជាតិ ក៏ត្រូវបានវាយតម្លៃថាមានកម្រិតបង្គួរ ខណៈដែលបណ្តាប្រទេសអាស៊ានដទៃទៀត ដែលបានធ្វើអង្កេតបង្ហាញថា ស្ថាប័នសវនកម្មកំពូលរបស់ពួកគេ មានភាពរឹងមាំ លើកលែងតែប្រទេសភូមា។ អង្កេត OBS ឆ្នាំ២០១២ បានវាយតម្លៃភាពខ្លាំងនេះ ដោយផ្អែកលើសមត្ថកិច្ចរបស់អាជ្ញាធរសវនកម្មជាតិ ក្នុងការដកហូតតំណែងប្រធានស្ថាប័ន អំណាចស្របច្បាប់ក្នុងការធ្វើសវនកម្មហិរញ្ញវត្ថុសាធារណៈ ធនធានហិរញ្ញវត្ថុដែលមាន និងការមានបុគ្គលិកជំនាញសវនកម្ម។

## ឱកាសសម្រាប់ការចូលរួមរបស់សាធារណជន

បទពិសោធន៍ស្រាវជ្រាវ និងតស៊ូមតិ របស់សង្គមស៊ីវិលក្នុងរយៈពេល ១៥ឆ្នាំមកនេះបានបង្ហាញថា តម្លាភាពតែមួយមុខមិនគ្រប់គ្រាន់សម្រាប់ការលើកកម្ពស់អភិបាលកិច្ចឡើយ។ ប៉ុន្តែ តម្លាភាព និងឱកាសសម្រាប់ការចូលរួមរបស់សាធារណជន ក្នុងការរៀបចំថវិកា អាចបង្កើនជាអតិបរមានូវលទ្ធផលវិជ្ជមានទាំងឡាយ ដែលមានទំនាក់ទំនងជាមួយការបើកចំហថវិកា។ ហេតុនេះ ទើបអង្កេត OBS វាយតម្លៃឱកាសដែលមាន សម្រាប់ឲ្យសាធារណជនចូលរួមក្នុងដំណើរការនានានៃការសម្រេចចិត្តស្តីពីថវិកាជាតិ។ ឱកាសបែបនេះ អាចផ្តល់បាននៅក្នុងដំណើរការថវិកាទាំងមូល ពីសំណាក់ស្ថាប័ននីតិប្រតិបត្តិ នីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល ហើយគប្បីត្រូវមានមូលដ្ឋានគតិយុត្តិ។

អង្កេត OBS ឆ្នាំ២០១២ ពិនិត្យឃើញថា ឱកាសសម្រាប់សាធារណជនចូលរួមក្នុងដំណើរការថវិកា នៅប្រទេសកម្ពុជាមានតិចតួច។ ហេតុនេះ ប្រទេសកម្ពុជានៅមានលទ្ធភាពច្រើនក្នុងការកែលម្អ ប្រសិនបើឱកាស[១២]មួយចំនួន មិនទាន់មានក្នុងពេលបច្ចុប្បន្ន ដូចជាការចូលរួមធ្វើកសិណសាក្សីរបស់សាធារណជន ក្នុងពេលប្រជុំពិភាក្សាពីថវិកានៅស្ថាប័ននីតិប្បញ្ញត្តិ និងយន្តការនានាបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានផ្តល់ឲ្យសាធារណជន សម្រាប់ការចូលរួមក្នុងពេលរៀបចំ និងអនុវត្តផែនការថវិកា។

[១២] សម្រាប់ព័ត៌មានលម្អិតអំពីឱកាសចូលរួមនានា ដែលប្រទេសកម្ពុជាអាចផ្តល់ឲ្យសាធារណជន សូមអានផ្នែកស្តីពីឱកាសសម្រាប់ការចូលរួមជាសាធារណៈ នៅក្នុងអត្ថបទសង្ខេបរបស់ IBP អំពីOBS ឆ្នាំ២០១២ សម្រាប់ ប្រទេសកម្ពុជា នៅលើគេហទំព័រ http://internationalbudget.org/wp-content/uploads/OBI2012-CambodiaCS-English.pdf។

## ស្ថានភាពជាសាកល នៃតម្លាភាពថវិកា ការត្រួតពិនិត្យ និងការចូលរួមរបស់សាធារណជន

អង្កេត OBS ឆ្នាំ២០១២ ពិនិត្យឃើញជាទូទៅថា ស្ថានភាពនៃតម្លាភាព និងគណនេយ្យភាពថវិកា មានសភាពគួរឲ្យព្រួយបារម្ភ។ ទោះជាយ៉ាងណាក៏ដោយ ពិន្ទុមធ្យមនៃតម្លាភាពថវិកា បានកើនឡើងជាបណ្តើរៗ ហើយជាពិសេសសម្រាប់បណ្តាប្រទេស ដែលធ្លាប់បានផ្តល់ព័ត៌មានថវិកាតិចបំផុត វឌ្ឍនភាពគឺមានល្បឿនស្មើរ និងគួរឲ្យកត់សម្គាល់។ ការរីកចម្រើនទាំងនេះ អាចសម្រេចទៅបាន ដោយសារប្រទេសទាំងនោះ បានប្រកាន់យកនូវជំហានរហ័សមួយ ដែលស្ទើរតែមិនមានការចំណាយអ្វីសោះ នោះគឺការផ្សព្វផ្សាយជាសាធារណៈនូវរាល់របាយការណ៍ថវិកា ដែលគេបានរៀបចំកន្លងមកសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងនៅលើគេហទំព័ររបស់ពួកគេ។

អង្កេត OBS ឆ្នាំ២០១២ បង្ហាញថា ប្រសិនបើរដ្ឋាភិបាលមានសុឆន្ទៈនយោបាយ នោះប្រទេសណាក៏អាចអនុវត្តបានល្អនូវតម្លាភាពថវិការបស់ខ្លួនដែរ ដោយមិនចោទលើទីតាំងភូមិសាស្ត្រ កម្រិតប្រាក់ចំណូល ឬការពឹងផ្អែកទៅលើប្រភេទប្រាក់ចំណូលជាក់លាក់ណាឡើយ។ បណ្តាប្រទេសពឹងផ្អែកខ្លាំងលើជំនួយ ដូចជាប្រទេសអាហ្វហ្គានីស្ថាន បណ្តាប្រទេសពឹងផ្អែកខ្លាំងលើចំណូលពីអ៊ីដ្រូកាបូន ដូចជាប្រទេសម៉ិចស៊ីកូ បណ្តាប្រទេសនៅមជ្ឈិមបូព៌ា និងប្រទេសនៅខាងត្បូងវាលខ្សាច់សាហារ៉ានៅទ្វីបអាហ្វ្រិក ដូចជាប្រទេសហ្សកដង់ អាហ្វ្រិកខាងត្បូង និងអ៊ូហ្គង់ដាជាដើម ប្រទេសទាំងអស់នេះសុទ្ធតែមានប្រព័ន្ធថវិកា ដែលមានតម្លាភាពជាបង្គួរ និងមានពិន្ទុ OBI ខ្ពស់ជាងច្រើនធៀបនឹងក្រុមប្រទេសក្នុងតំបន់របស់ពួកគេ។

ឱកាសចូលរួមជាសាធារណៈក្នុងដំណើរការថវិកា នៅក្នុងប្រទេសភាគច្រើន មានតិចតួច ឬគ្មានសោះតែម្តង ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងបញ្ហាកង្វះតម្លាភាព។ ប្រទេសចំនួន ៨ ពុំមានឱកាសបែបនេះនោះទេ មានន័យថា ប្រជាពលរដ្ឋនៃប្រទេសទាំងនោះត្រូវបានគេផ្តាច់ចេញទាំងស្រុងពីការពិភាក្សា និងការតាមដានថវិកា។ ទោះជាយ៉ាងណាក្តី តាមការពិនិត្យឃើញរបស់អង្កេត OBS ឆ្នាំ២០១២ គំនិតផ្តួចផ្តើមដ៏គួរឲ្យសង្ឃឹមមួយចំនួនកំពុងតែបោះជំហានទៅមុខ ដូចជា កិច្ចពិភាក្សាជាសាធារណៈអំពីសេចក្តីព្រាងច្បាប់ថវិកានៅប្រទេសកូរ៉េខាងត្បូង និងប្រទេសម៉ាឡាវី និងប្រព័ន្ធ "ផ្តល់ដំណឹងអំពីការលួចបន្លំ" ដែលអាចប្រើប្រាស់បានតាមរយៈគេហទំព័ររបស់ស្ថាប័នសវនកម្មកំពូលនៅប្រទេសហ្វីលីពីន។ ទាំងនេះបង្ហាញថា ការផ្តល់ឱកាសសម្រាប់ការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា អាចអនុវត្តដោយរដ្ឋាភិបាលណាក៏បាន ហើយយន្តការសម្រាប់ឱកាសទាំងនេះ មិនចាំបាច់រង់ចាំរហូតទាល់តែមានការពង្រីកជាមុននូវតម្លាភាពថវិកានោះទេ។

អង្កេត OBS ឆ្នាំ២០១២ ក៏ពិនិត្យឃើញផងដែរថា ស្ថាប័នត្រួតពិនិត្យ (អង្គនីតិប្បញ្ញត្តិ និងស្ថាប័នសវនកម្មកំពូល) ជាមធ្យមមានអំណាចបង្គួរ និងលើបង្គួរមួយកម្រិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ច្រើនតែប្រឈមមុខនឹងឧបសគ្គធ្ងន់ធ្ងរ រាប់ទាំងកង្វះធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ហើយភាពនៅមានកំណត់នៃអាណត្តិការងារ និងឯករាជ្យភាព។ បន្ថែមលើនេះទៀត ស្ថាប័នទាំងនេះជារឿយៗត្រូវបានរារាំង ដោយកង្វះយន្តការទាំងឡាយ ដែលជំនួយដល់ពួកគេក្នុងការធ្វើសកម្មភាពនានា ដើម្បីបន្តតាមដានលើការឆ្លើយតបនឹងបញ្ហាដែលខ្លួនរកឃើញ។ អ្វីដែលជាកង្វល់ធំបំផុតនោះគឺថា បណ្តាប្រទេសដែលមានស្ថាប័នត្រួតពិនិត្យខ្សោយ ជារឿយៗ គឺជាបណ្តាប្រទេសដែលមិនសូវមានតម្លាភាពថវិកា ហើយផ្តល់ឱកាសតិចតួចឲ្យសាធារជនចូលរួម។

## ការពណ៌នាអំពីអង្កេត វិធីសាស្ត្រ និងភាពជឿជាក់បាន

អង្កេត OBS គឺជាឧបករណ៍ស្រាវជ្រាវ ដែលមានមូលដ្ឋានផ្អែកលើតថភាព និងប្រើប្រាស់បាតុភូតដែលងាយសង្កេត ដើម្បីវាយតម្លៃនូវអ្វីដែលកើតឡើងក្នុងការអនុវត្តជាក់ស្តែង។ សេចក្តីសន្និដ្ឋាននានាពីការស្រាវជ្រាវ ជាទូទៅមានការយោងច្បាស់លាស់ទៅលើប្រភព និងមតិយោបល់ រាប់ទាំងការយោងដល់ឯកសារថវិកា ច្បាប់ ឬឯកសារសាធារណៈដទៃទៀត សេក្តីថ្លែងការជាសាធារណៈរបស់មន្ត្រីរដ្ឋាភិបាល ឬយោបល់បានពីកិច្ចសម្ភាសន៍ទល់មុខគ្នាជាមួយមន្ត្រីរដ្ឋាភិបាល ឬជាមួយភាគីដឹងរឿងដទៃទៀត។ អង្កេតនេះត្រូវបានធ្វើឡើងពីកម្រងសំណួរ ដែលបានបំពេញសម្រាប់ប្រទេសនីមួយៗដោយអ្នកជំនាញឯករាជ្យ ដែលមិនជាប់ពាក់ព័ន្ធជាមួយរដ្ឋាភិបាលឡើយ។ បន្ទាប់មកកម្រងសំណួររបស់ប្រទេសនីមួយៗ ត្រូវបានពិនិត្យមើលសារឡើងវិញដោយអ្នកជំនាញអនាមិកពីររូប ដែលអ្នកទាំងនេះក៏មិនជាប់ពាក់ព័ន្ធជាមួយរដ្ឋាភិបាលដែរ។ បន្ថែមពីលើនេះ អង្គការ IBP ក៏អញ្ជើញរដ្ឋាភិបាលនៃប្រទេសនីមួយៗ ឲ្យផ្តល់មតិលើសេចក្តីព្រាងលទ្ធផលអង្កេតនេះ ហើយពិចារណាយោបល់ទាំងនេះ មុនពេលបញ្ចប់នូវលទ្ធផលអង្កេត។ ដំណើរការស្រាវជ្រាវទាំងមូលសម្រាប់ឆ្នាំ២០១២ នេះ មានរយៈពេល ១៨ខែ គឺក្នុងចន្លោះពីខែកក្កដា ឆ្នាំ២០១១ ដល់ខែធ្នូ ឆ្នាំ២០១២ ហើយមានអ្នកជំនាញប្រមាណជា ៤០០នាក់ បានចូលរួម។

អង្កេត OBS ផ្តល់នូវប្រភពទិន្នន័យមួយ ដែលអាចជឿទុកចិត្តបានស្តីពីការអនុវត្តតម្លាភាពថវិកាជាតិ ដល់រដ្ឋាភិបាល អ្នកធ្វើការពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ប្រព័ន្ធផ្សព្វផ្សាយ និងប្រជាពលរដ្ឋ។ អ្នកកំពុងប្រើប្រាស់លទ្ធផលនៃអង្កេតនេះរួមមាន ភាពជាដៃគូនៃរដ្ឋាភិបាលបើកចំហ (Open Government Partnership) គំនិតផ្តួចផ្តើមសហការលើកំណែទម្រង់ថវិកាអាហ្វ្រិក (Collaborative Africa

Budget Reform Initiative) អង្គការស្ថាប័នសវនកម្មកំពូលអន្តរជាតិ (International Organization of Supreme Audit Institutions-INTOSAI) ធនាគារពិភពលោក សម្រាប់សូចនាករអភិបាលកិច្ចសាកល (Worldwide Governance Indicators) របស់ខ្លួន និងទីភ្នាក់ងារជំនួយទ្វេភាគីមួយចំនួន ព្រមទាំងស្ថាប័នពហុភាគីក្នុងតំបន់ និងអន្តរជាតិឯទៀត។ ការបោះផ្សាយនូវលទ្ធផលនៃអង្កេត OBS ឆ្នាំ២០១២ បានពង្រឹងនូវតួនាទីកាន់តែសំខាន់របស់អង្កេតនេះជាឃ្លាំងទិន្នន័យសាកលស្តីពីតម្លាភាពថវិកា ការចូលរួម និងគណនេយ្យភាព។

## អនុសាសន៍

ជាមួយស្ថានភាពបច្ចុប្បន្នអំពីតម្លាភាពថវិកា និងការត្រួតពិនិត្យ ព្រមទាំងការចូលរួមជាសាធារណៈ ប្រទេសកម្ពុជាមានឱកាសច្រើនសម្រាប់ការកែលម្អ តាមរយៈការដាក់ឲ្យប្រើនូវវិធានការខាងក្រោម ដែលក្នុងនោះ មានវិធានការមួយចំនួនអាចសម្រេចបានយ៉ាងឆាប់រហ័ស និងស្ទើរតែមិនមានការចំណាយអ្វីសោះ ដូចជាៈ

- ផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ថវិកា របាយការណ៍ពាក់កណ្តាលឆ្នាំ និងរបាយការណ៍សវនកម្មផ្ទៃក្រៅ (ដោយអាជ្ញាធរសវនកម្មជាតិ) ជូនដល់សាធារណជនឲ្យបានទាន់ពេលវេលា និងទៀងទាត់។
- ផ្សព្វផ្សាយរាល់ច្បាប់ថវិកា និងច្បាប់ទូទាត់ថវិកាដែលបានអនុម័ត នៅលើគេហទំព័រ[១៣]របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ផលិត និងផ្សព្វផ្សាយឯកសារថវិកាសម្រាប់ប្រជាពលរដ្ឋ និងឯកសារណែនាំពាក់ព័ន្ធនានា សម្រាប់ឆ្លើយតបនឹងបញ្ហាបច្ចេក-ទេស នៃដំណើរការ និងបច្ចេកស័ព្ទថវិកា។
- បង្កើនភាពគ្រប់ជ្រុងជ្រោយនៃ **របាយការណ៍បុរេថវិកា** តាមរយៈការពន្យល់ពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធរបស់រាជរដ្ឋាភិបាល ភាពគ្រប់ជ្រុងជ្រោយនៃ**របាយការណ៍ក្នុងឆ្នាំ** តាមរយៈការផ្តល់ព័ត៌មានស្តីពីសមាសភាពបំណុលរាជរដ្ឋាភិបាល និង ភាពគ្រប់ជ្រុងជ្រោយនៃ**របាយការណ៍ដំណាច់ឆ្នាំ** តាមរយៈការពន្យល់ពីភាពខុសគ្នារវាង កម្រិតចំណាយដែលបានអនុម័ត និងលទ្ធផលជាក់ស្តែងនៃចំណាយ និងរវាងការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចកាលពីដំបូង និងលទ្ធផលជាក់ស្តែងសម្រាប់ឆ្នាំថវិកា។
- ពង្រីកការចូលរួមជាសាធារណៈ តាមរយៈការផ្តល់ឲ្យសាធារណ-ជនធ្វើកសិណសាក្សីក្នុងកិច្ចប្រជុំ ឬកិច្ចពិភាក្សារបស់ស្ថាប័ននីតិប្បញ្ញត្តិស្តីពីថវិកា រាប់ទាំងការពិភាក្សានៅក្នុងគណៈកម្មការទី ២ នៃរដ្ឋសភាជាតិ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។ ចំណុចនេះអាចធ្វើទៅបាន ប្រសិនបើគណៈកម្មការទី២ រៀបចំកិច្ចប្រជុំជាសាធារណៈ មុនពេលការជជែកដេញដោលនៅសភាពេញអង្គលើសេចក្តីព្រាងច្បាប់ថវិកា និងអញ្ជើញសាធារណជន អង្គការសង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវ ស្ថាប័នស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយ និងក្រុមដែលមានចំណាប់អារម្មណ៍ដទៃទៀត។
- បង្កលក្ខណៈឲ្យស្ថាប័ននីតិប្បញ្ញត្តិធ្វើការត្រួតពិនិត្យ បានគ្រប់ជ្រុងជ្រោយលើដំណើរការថវិកា តាមរយៈការផ្តល់ព័ត៌មានថវិកាពេញលេញបន្ថែមទៀត នៅក្នុងឯកសារថវិកាទាំងឡាយ ដែលផ្ញើជូននិងរាយការណ៍ទៅកាន់រដ្ឋសភាជាតិ។
- ផ្តល់អំណាចជូនអាជ្ញាធរសវនកម្មជាតិ តាមរយៈការបង្កើនថវិកាស្ថាប័ននេះសម្រាប់រយៈពេលខ្លី និងកំណត់ក្នុងច្បាប់ឲ្យថវិកាសម្រាប់អាជ្ញាធរសវនកម្មជាតិ ត្រូវកំណត់ដោយស្ថាប័ននីតិប្បញ្ញត្តិ ឬដោយស្ថាប័នតុលាការ។

## ហេតុអ្វីបានជារាជរដ្ឋាភិបាលកម្ពុជា គួរផ្សព្វផ្សាយឯកសារថវិកាទាំងនេះ?

ជម្រើសរបស់រាជរដ្ឋាភិបាលក្នុងការផ្សព្វផ្សាយឯកសារថវិកាទាំងនេះឲ្យបានទាន់ពេលវេលា ផ្តល់នូវសារមួយដ៏មានទម្ងន់ទៅកាន់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតរបស់ខ្លួន។ ការផ្សព្វផ្សាយនូវព័ត៌មានថវិកាខាងលើ នឹងផ្តល់ផលជាវិជ្ជមាន ជាជាងផលលំបាក នៅក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ សម្រាប់រាជរដ្ឋាភិបាល ក៏ដូចជាប្រទេសកម្ពុជាទាំងមូល។ ទង្វើនេះបង្កឲ្យមានការចូលរួម ជាសាធារណៈច្រើនបន្ថែមទៀតនៅក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ ដែលរាជរដ្ឋាភិបាលកំពុងតែយកចិត្តទុកដាក់ ពីព្រោះបើមិនមានព័ត៌មានថវិកានោះទេ នោះសាធារណជននឹងមិនមានអារម្មណ៍កក់ក្តៅ និងជឿជាក់ឡើយ ជាមួយនឹងមាត្រាមួយនៃ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ[១៤]។ អំណះអំណាងដ៏ជាក់លាក់មួយគឺថា ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល អាចមិនហ៊ានប្តឹងចោទដោយផ្ទាល់ពីបទសង្ស័យអំពើពុករលួយដល់ស្ថាប័ន ឬបុគ្គលណាឡើយ នៅពេលដែលមិនមានព័ត៌មានថវិកាដ៏គ្រប់ជ្រុងជ្រោយ ដែលផ្សព្វផ្សាយជាសាធារណៈ និងដែលពួកគេអាចប្រើប្រាស់បានសម្រាប់យោងដល់ការប្តឹងចោទពីបទសង្ស័យណាមួយ។

---

[១៣] នៅលើគេហទំព័រនេះ គេឃើញមានតែច្បាប់ទូទាត់ថវិកាឆ្នាំ២០០៨ និងឆ្នាំ២០០៩ ប៉ុណ្ណោះ គិតត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ហើយរាល់ច្បាប់ថវិកាទាំងអស់ដែលបានអនុម័ត មិនត្រូវបានដាក់នៅក្នុងគេហទំព័រតែមួយ ដើម្បីសម្រួលដល់ការស្វែងរកជាសាធារណៈឡើយ។

[១៤] មាត្រា៤១ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានអង្គការសង្គមស៊ីវិលជាច្រើនរិះគន់ថាជា ការគំរាមកំហែងមួយដល់ការលើកទឹកចិត្តឲ្យមានការចូលរួមជាសាធារណៈ នៅក្នុងយុទ្ធនាកាប្រឆាំងអំពើពុករលួយ។ មាត្រានេះចែងថា “អំពើប្តឹងបរិហារដោយភូតកុហកដល់អង្គភាពប្រឆាំងអំពើពុករលួយ ឬតុលាការនូវអង្គហេតុបទល្មើសពុករលួយ កាលបើអំពើនេះនាំឱ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ទៅប្រាំឆ្នាំ និងពិន័យជាប្រាក់ពីមួយសែនរៀល ទៅបួនលានរៀល”។

ទង្វើខាងលើនេះក៏បង្ហាញផងដែរថា រាជរដ្ឋាភិបាលមានការប្តេជ្ញាអំពីតម្លាភាព និងគណនេយ្យភាព លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អំណះអំណាងទាំងឡាយខាងក្រោម បង្ហាញពីហេតុផល ដែលរដ្ឋាភិបាលគប្បីគួរមានការបើកចំហច្រើនបន្ថែមទៀត ក្នុងការគ្រប់គ្រងថវិកា ដែលចំនុចទាំងនេះគួរទទួលបានការពិចារណាពីសំណាក់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ពន្ធ័ទៀត។ ជាមួយនឹងកម្រិតតម្លាភាពសមរម្យមួយ៖

- ប្រជាពលរដ្ឋអាចដឹងបាន (ទាំងស្រុង) អំពីសមិទ្ធិផលរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបានការងារបច្ចុប្បន្នលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអាចចូលរួមបានយ៉ាងសកម្មបន្ថែមទៀត នៅក្នុងដំណើរការថវិកាសំដៅបំពេញចន្លោះប្រហោងនៅក្នុងការត្រួតពិនិត្យ និងតុល្យភាពរវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិប្បញ្ញត្តិ។
- ទស្សនៈសាធារណៈលើឯករាជ្យភាពនៃអាជ្ញាធរសវនកម្មជាតិ ពីសំណាក់រាជរដ្ឋាភិបាល នឹងអាចត្រូវបានកែលម្អតាមរយៈការផ្សព្វផ្សាយរបាយការណ៍សវនកម្មឲ្យបានទាន់ពេលវេលា ដែលអនុញ្ញាតឲ្យរដ្ឋសភាអាចទាមទាររាជរដ្ឋាភិបាល មានគណនេយ្យភាពលើការអនុវត្តថវិកា។
- ប្រជាពលរដ្ឋអាចនឹងមើលឃើញ ថាតើប្រព័ន្ធថវិការបស់រាជរដ្ឋាភិបាល មានប្រសិទ្ធភាព និងប្រសិទ្ធផលយ៉ាងដូចម្តេច ក្នុងការរួមចំណែកដល់ការសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ ដូចដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។
- កិត្តិនាមរបស់ប្រទេសកម្ពុជា ដែលឆ្លុះបញ្ចាំងដោយចំណាត់ថ្នាក់តម្លាភាពថវិកាអន្តរជាតិថាបានប្រសើរឡើង នឹងអាចជួយដល់រាជរដ្ឋាភិបាលយ៉ាងហោចណាស់មួយផ្នែក ក្នុងការទាក់ទាញការវិនិយោគដោយផ្ទាល់ពីបរទេស ក៏ដូចជាការគ្រប់គ្រងជំនួយអភិវឌ្ឍន៍ ឲ្យឆ្លើយតបទៅនឹងរបៀបវារៈអភិវឌ្ឍន៍ប្រទេសកម្ពុជា។
- តម្លាភាពនឹងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ក៏ដូចជា អនុវត្តឲ្យបានជោគជ័យនូវច្បាប់ប្រឆាំងអំពើពុករលួយ និងទាញយកមកវិញនូវធនធានដែលធ្លាប់បាត់បង់ សម្រាប់ជាប្រយោជន៍ដល់ការវិនិយោគ និងប្រតិបត្តការរដ្ឋបាលចាំបាច់ ដូចជាការលើកបង្កើនបៀវត្សរ៍របស់មន្ត្រីស៊ីវិលសាធារណៈ ឲ្យបានដល់កម្រិតមួយដែលអាចផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគាត់បាន។
- តម្លាភាពនឹងរួមចំណែកផងដែរដល់កិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលក្នុងការប្រមូលពន្ធ និងចំណូលក្នុងស្រុកដទៃទៀត ដែលអាចជួយកាត់បន្ថយការពឹងផ្អែករបស់ប្រទេសកម្ពុជាទៅលើជំនួយបរទេស និងលើសពីនេះទៅទៀត ជួយដល់រាជរដ្ឋាភិបាលឲ្យមានលទ្ធភាពក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និងគោលនយោបាយបែងចែកឡើងវិញឲ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពជាងមុន ដូចជាពន្លឿនការអនុវត្តកម្មវិធីសំណាញ់សុវត្ថិភាពសង្គម ឬកម្មវិធីគាំពារសង្គម ការផ្តល់សម្បទានដីសង្គមកិច្ច និងកម្មវិធីដទៃទៀតសម្រាប់ក្រុមជនក្រីក្រ និងងាយរងគ្រោះ។

# សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា



## ភាពជាដៃគូថវិកាអន្តរជាតិ

អង្គការភាពជាដៃគូថវិកាអន្តរជាតិ (IBP) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៧ ដើម្បីធ្វើការសហការជាមួយអង្គការសង្គមស៊ីវិល នៃប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការវិភាគ តាមដាន និងធ្វើឲ្យមានឥទ្ធិពលលើដំណើរការថវិកា ស្ថាប័ន និងលទ្ធផលការងាររបស់រដ្ឋាភិបាល។ IBP ជាផ្នែកមួយនៃមជ្ឈមណ្ឌលស្តីពីអាទិភាពថវិកា និងគោលនយោបាយ ដែលជាអង្គការស្រាវជ្រាវមិនបម្រើឲ្យគណបក្សនយោបាយ និងមិនស្វែងរកប្រាក់ចំណេញ ហើយមានទីស្នាក់ការនៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី នៃសហរដ្ឋអាមេរិច។ ភាពជាដៃគូនេះមានគោលបំណងធ្វើឲ្យប្រព័ន្ធថវិកាកាន់តែមានលក្ខណៈឆ្លើយតបច្រើនឡើងទៅនឹងសេចក្តីត្រូវការរបស់ប្រជាជនក្រីក្រ និងប្រជាជនមានប្រាក់ចំណូលទាបនៅក្នុងសង្គម និងដោយហេតុនេះ សំដៅធ្វើឲ្យប្រព័ន្ធទាំងនេះកាន់តែមានតម្លាភាព និងគណនេយ្យភាពចំពោះសាធារណជន។ សម្រាប់ព័ត៌មានបន្ថែមស្តីពី IBP និងគំនិតផ្តួចផ្តើមការផ្សព្វផ្សាយព័ត៌មាន សូមមើលគេហទំព័រ៖

www.internationalbudget.org និង www.openbudgetindex.org។

INTERNATIONAL BUDGET PARTNERSHIP
Open Budgets. Transform Lives.

820 First Street, NE Suite 510, Washington, DC 20002 U.S.
Tel: +1 202 408 1080 | Fax: +1 202 408 8173
Email: info@international.org

## វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គឺជាអង្គការសមាជិកភាពមួយ ដែលរួមមានអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការនៅប្រទេសកម្ពុជា។ អង្គការនេះបង្កើតឡើងដើម្បីចែករំលែកព័ត៌មាន ពិភាក្សាដេញដោល និងតស៊ូមតិលើបញ្ហាអាទិភាពនានា ដែលប៉ះពាល់ដល់ការអភិវឌ្ឍប្រទេសកម្ពុជា។ ដោយបានទទួលការឧបត្ថម្ភគាំទ្រមួយផ្នែកពី អង្គការភាពជាដៃគូថវិកាអន្តរជាតិ គម្រោងថវិកាជាតិរបស់ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានធ្វើការតស៊ូមតិលើតម្លាភាពថវិកានៅថ្នាក់ជាតិ តាមរយៈការបង្កើតឱកាសដើម្បីសុំឲ្យរដ្ឋាភិបាលផ្សព្វផ្សាយព័ត៌មានថវិកាឲ្យបានទូលំទូលាយ និងកែលម្អភាពទុកចិត្តបាន និងអាទិភាពរបស់ថវិកា។ សម្រាប់ព័ត៌មានបន្ថែមស្តីពី វេទិកានៃអង្គកាមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមមើលគេហទំព័រ៖

www.ngoforum.org.kh និង www.cambodianbudget.org។

**បោះពុម្ពផ្សាយដោយ៖**
**គម្រោងថវិកាជាតិ នៃកម្មវិធីបញ្ហាអភិវឌ្ឍន៍**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការប្រសើរឡើង
Working Together for Positive Change

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់
ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ៣
ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៤ ៤២៩
ទូរសារ៖ (៨៥៥) ២៣ ៩៩៤ ០៦៣
អ៊ីម៉េល៖ ngoforum@ngoforum.org.kh